**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃ ការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

### ប្រការ១ .-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ ដែលសរសេរជាអក្សរកាត់ថា **គ.ត.គ.ស** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកជំទាវ **ចម និម្មល** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- ឯកឧត្តម **ឌួច ម៉ុនហួរ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣- ឯកឧត្តម **សុន សេងហួត** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ទ៉ា រុតសាន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥- ឯកឧត្តម **រាជ រ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- ឯកឧត្តម **ទេព តិយ៉ោវិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |



https://www.moj.gov.kh/kh/law-regular

| | | |
|---|---|---|
| ៧- ឯកឧត្តម **អ៊ុត សំអន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៩- ឯកឧត្តម **សុត រស្មី** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១០- ឯកឧត្តម **អ៊ុន វ៉ាល់ឡឺរ៉ូ** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១- ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១២- ឯកឧត្តម **គុយ ឆាយ** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣- ឯកឧត្តម **សាម អ៊ីន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៤- ឯកឧត្តម **ប៉ោ និមល** | អនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៥- ឯកឧត្តម **កៅ គោសល** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម | សមាជិក |
| ១៦- ឯកឧត្តម **សំរិទ្ធ សាកុរា** | អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៧- ឯកឧត្តម **នុត អ៊ុនវ័ណរ៉ា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៨- ឯកឧត្តម **ភាន់ ឬទ្ធី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ | សមាជិក |
| ១៩- ឯកឧត្តម **ចាន់ សីហា** | អគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម | សមាជិក |
| ២០- លោក **សែ សុឃន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២១- ឯកឧត្តម **គន់ សារ៉ា** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គមនិងគ្រប់គ្រងទិន្នន័យ នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ២២- លោក **ឡាយ សុខហេង** | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៣- លោក **នៀម សុគន្ធ** | នាយកប្រតិបត្តិប្រតិបត្តិការ នៃធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា | សមាជិក |
| ២៤- លោក **ខឹម ម៉ាអ់ស៊ីនី** | នាយកបញ្ជីថ្លៃលក់ នៃអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ២៥- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក។ |

**គ.ត.គ.ស** អាចមានសមាសភាពមកពីក្រសួង ស្ថាប័នផ្សេងទៀត តាមការចាំបាច់។



https://www.moj.gov.kh/kh/law-regular

**ប្រការ២.-**

គ.ត.គ.ស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- តាមដាន និងវាយតម្លៃការអនុវត្តដោយផ្ទៀងផ្ទាត់គោលដៅ និងផែនការសកម្មភាពនៃគោលនយោបាយជាតិស្តីពីស្វាយចន្ទី
- កំណត់សូចនាករវាស់វែងសមិទ្ធកម្មគោលដៅ និងលទ្ធផលអនុវត្តផែនការសកម្មភាព
- សម្របសម្រួល ជំរុញ និងរៀបចំលើការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី
- បង្កើតយន្តការដើម្បីប្រមូលព័ត៌មាន តាមដាន ត្រួតពិនិត្យ កែតម្រូវ និងរៀបចំរបាយការណ៍វាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ព្រមទាំងលើកទិសដៅអនុវត្តបន្ត
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣.-**

គ.ត.គ.ស ត្រូវប្រជុំយ៉ាងតិច ១(មួយ)ដង ក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញ។

អនុប្រធាន និងសមាជិក នៃ គ.ត.គ.ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

ក្នុងករណីអនុប្រធាន ឬសមាជិកអវត្តមាន ត្រូវចាត់តាំងតំណាងឱ្យចូលរួមប្រជុំជំនួស។

**ប្រការ៤.-**

ប្រធាន គ.ត.គ.ស មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន អាជ្ញាធរ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលពុំមានចែងក្នុងប្រការ១ នៃសេចក្តីសម្រេចនេះចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៥.-**

គ.ត.គ.ស មានអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានមានសមាសភាពជាតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

អគ្គនាយក នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ជាប្រធានលេខាធិការដ្ឋាន នៃ គ.ត.គ.ស។

ប្រធានលេខាធិការដ្ឋាន នៃ គ.ត.គ.ស មានសិទ្ធិប្រើមន្ត្រីនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មក្នុងការបំពេញភារកិច្ចរបស់ខ្លួន។



https://www.moj.gov.kh/kh/law-regular

**ប្រការ៦ ._**

លេខាធិការដ្ឋាន នៃ **គ.ត.គ.ស** មានតួនាទី និងភារកិច្ចដូចតទៅ៖

- សម្របសម្រួល និងរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្ត គោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧
- សម្របសម្រួលលើការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧
- រៀបចំវេទិកាស្វាយចន្ទីថ្នាក់ជាតិនៅតាមបណ្តាខេត្តសក្តានុពល
- ចូលរួមវេទិកាថ្នាក់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យស្វាយចន្ទី
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់លើការអភិវឌ្ឍវិស័យស្វាយចន្ទីនៅកម្ពុជា
- ចុះពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងទទួលសំណូមពររបស់សហព័ន្ធ សមាគម សហគមន៍ អ្នកផលិត និងប្រជាកសិករសម្រាប់ជាធាតុចូលក្នុងការស្វែងរកដំណោះស្រាយសមស្របពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្ម
- ប្រមូល ចងក្រង បោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ស្តីពីវឌ្ឍនភាពលើសកម្មភាព និងទិសដៅបន្ត នៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧
- សហការ និងសម្របសម្រួលរៀបចំរបាយការណ៍ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ត.គ.ស**។

**ប្រការ៧ ._**

**គ.ត.គ.ស** មានសិទ្ធិប្រើទីតាំង រូបសញ្ញា និងត្រារបស់ក្រសួងពាណិជ្ជកម្មក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៨ ._**

**គ.ត.គ.ស** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកពីក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។

**គ.ត.គ.ស** មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងប្រើប្រាស់ស្របតាមច្បាប់ជាធរមាន នូវធនធាន និងមូលនិធិបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៩ ._**

សេចក្តីសម្រេចលេខ៤៧ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។



https://www.moj.gov.kh/kh/law-regular

**ប្រការ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular